**ព្រឹត្តិប័ត្រសារព័ត៌មាន** **១៥ មករា ២០២៦**

# ការចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នា ជាដៃគូយុទ្ធសាស្ត្រជាផ្លូវការ ក្នុងការពង្រឹងប្រព័ន្ធអេកូឡូស៊ីសហគ្រាសធុនតូច និងមធ្យម (SME) រវាងធនាគារ មេយប៊ែង និង សហគ្រិនខ្មែរ (KE)

**រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦ —** ធនាគារ មេយប៊ែង ខេមបូឌា និងសហគ្រិនខ្មែរ (KE) បានធ្វើការចុះហត្ថលេខា ភាពជាដៃគូយុទ្ធសាស្ត្រជាផ្លូវការ ដើម្បីពង្រឹងការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម (SMEs) នៅក្នុងប្រទេសកម្ពុជា ព្រមទាំងពង្រឹងការប្តេជ្ញាចិត្តរួមគ្នាក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាពនៅទូទាំងប្រទេស។

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាដៃគូយុទ្ធសាស្ត្រនេះ ធ្វើឡើងនៅស្នាក់ការកណ្តាលរបស់ធនាគារ មេយប៊ែង រាជធានីភ្នំពេញក្រោមវត្តមានរបស់លោក រ័ត្ន សោភ័ណ នាយកប្រតិបត្តិ និងនាយកប្រចាំប្រទេស នៃធនាគារ មេយប៊ែង ខេមបូឌា និងឯកឧត្តម បណ្ឌិត ឈៀង វណ្ណមុនិណ្ណ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកប្រតិបត្តិ នៃសហគ្រិនខ្មែរ។

ភាពជាដៃគូនេះ បាននាំមកនូវកិច្ចសហការរវាងធនាគារ មេយប៊ែង និងសហគ្រិនខ្មែរ ដើម្បីលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពឱ្យកាន់តែរឹងមាំ និងមានចីរភាពសម្រាប់សហគ្រិន អាជីវកម្មថ្មី និងសហគ្រាសធុនតូច និងមធ្យមនៅទូទាំងប្រទេសកម្ពុជា។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ ស្ថាប័នទាំងពីរនឹងធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន ពង្រឹងសមត្ថភាពអាជីវកម្ម និងលើកកម្ពស់ការត្រៀមខ្លួនរបស់សហគ្រាសធុនតូច និងមធ្យមលើផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុឲ្យកាន់តែល្អប្រសើរ និងមានលក្ខណៈជាដំណាក់កាល។

ជុំវិញការថ្លែងមតិស្តីពីភាពជាដៃគូនេះ លោក រ័ត្ន សោភ័ណ បានមានប្រសាសន៍ថា៖ «កិច្ចសហប្រតិបត្តិការនេះ បានសម្គាល់ នូវភាពសំខាន់ជាមួយកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់ធនាគារ ក្នុងការគាំទ្រដល់សហគ្រាសនៅកម្ពុជា។ លោកបានបន្ថែមទៀតថា ភាពជាដៃគូនេះ បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ធនាគារ មេយប៊ែង ក្នុងការផ្តល់ជូននូវសេវាហិរញ្ញវត្ថុប្រកបដោយអារិយភាព តាមរយៈការផ្តល់ជូននូវដំណោះស្រាយហិរញ្ញវត្ថុ ជាមួយនឹងចំណេះដឹង និងភាពជាដៃគូរយៈពេលយូរអង្វែងដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីឲ្យមានការរីកចម្រើនប្រកបដោយចីរភាព។»

ស្របជាមួយនឹងការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ី ឯកឧត្តម បណ្ឌិត ឈៀង វណ្ណមុនិណ្ណ បានគូសបញ្ជាក់ថា៖ «ភាពជាដៃគូនេះគឺតំណាងឲ្យការបោះជំហានទៅមុខដ៏សំខាន់មួយសម្រាប់ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពរបស់កម្ពុជា។ កិច្ចសហការនេះនឹងជួយបង្កើន និងពង្រីកការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម (SMEs) តាមរយៈការកែលម្អលើលទ្ធភាពទទួលបានផ្នែកហិរញ្ញប្បទាន។ ទន្ទឹមនឹងនេះ សហគ្រិនខ្មែរ ក៏សូមអំពាវនាវដល់ធនាគារពាណិជ្ជផ្សេងៗទៀត ឲ្យចូលរួមគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការលើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញវត្ថុឲ្យកាន់តែប្រសើរឡើង ការសម្របសម្រួលនីតិវិធីឲ្យមានភាពសាមញ្ញ និងការផ្តល់នូវលក្ខខណ្ឌហិរញ្ញប្បទានកាន់តែអំណោយផល ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

នៅក្រោមកិច្ចសហប្រតិបត្តិការនេះ សហគ្រិនខ្មែរ នឹងរួមចំណែកដល់ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព តាមរយៈការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការសម្របសម្រួលទំនាក់ទំនងរវាងសហគ្រាសធុនតូច និងមធ្យម (SMEs) ជាមួយធនាគារ មេយប៊ែង និងការបង្កើតកម្មវិធីយុទ្ធសាស្ត្រនានា ដែលតម្រូវទៅតាមតម្រូវការរបស់សហគ្រាសធុនតូច និងមធ្យម (SMEs) ដើម្បីធានាថាពួកគេអាចទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុប្រកបដោយជោគជ័យ ចំណែកឯធនាគារ មេយប៊ែង សហការជាមួយសហគ្រិនខ្មែរ នឹងជួយគាំទ្របង្កើនការយល់ដឹងអំពីលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) នៅក្នុងប្រទេសកម្ពុជា តាមរយៈការចែករំលែកនូវការអនុវត្តល្អៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការពង្រឹងការត្រៀមខ្លួនរបស់សហគ្រាសធុនតូច និងមធ្យម ក្នុងការប្រើប្រាស់សេវាកម្មធនាគារ និងផ្តល់ជូននូវដំណោះស្រាយហិរញ្ញប្បទាន ដែលស្របតាមលក្ខខណ្ឌដែលមានជាធរមាន។

ភាពជាដៃគូនេះ បានឆ្លុះបញ្ចាំងពីកាតព្វកិច្ចរបស់ធនាគារ មេយប៊ែង ក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុ ដែលផ្តល់ទំនុកចិត្តខ្ពស់ទៅកាន់អតិថិជនដោយប្រើប្រាស់បណ្តាញទំនាក់ទំនងសម្ព័ន្ធធនាគារ មេយប៊ែង រួមជាមួយការយល់ដឹងយ៉ាងច្បាស់លាស់អំពីបរិបទក្នុងស្រុក ដើម្បីផ្តល់ជូននូវសេវាហិរញ្ញវត្ថុប្រកបដោយចីរភាព ដែលរួមមាន៖ ដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធិភាព ការយល់ដឹងស៊ីជម្រៅក្នុងតំបន់ និងសេវាកម្មធនាគារដែលផ្អែកលើការកសាងទំនាក់ទំនង។ ទន្ទឹមនឹងនេះដែរ កិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងបេសកកម្មរបស់សហគ្រិនខ្មែរ ក្នុងនាមជាវេទិកាជាតិសម្រាប់គាំទ្រដល់សហគ្រិន អាជីវកម្មថ្មីៗ និងសហគ្រាសធុនតូច និងមធ្យម (SMEs) តាមរយៈការកសាងសមត្ថភាព ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ី និងការសម្របសម្រួលជាមួយឱកាសទីផ្សារ និងលទ្ធភាពទទួលបានហិរញ្ញវត្ថុ។ ស្ថាប័នទាំងពីរបានសង្កត់ធ្ងន់លើសារៈសំខាន់ នៃកិច្ចសហប្រតិបត្តិការឆ្លងវិស័យ ក្នុងការពង្រឹងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពរបស់កម្ពុជា ដើម្បីអនុញ្ញាតឲ្យសហគ្រាសធុនតូច និងមធ្យមអាចដោះស្រាយបញ្ហាដែលកំពុងប្រឈមលើផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុឲ្យបានកាន់តែប្រសើរ និងបង្កើនភាពរឹងមាំ នៃប្រតិបត្តិការផ្នែកអាជីវកម្ម ក៏ដូចជាទទួលបានឱកាសជាច្រើនក្នុងការអភិវឌ្ឍន៍ខ្លួននៅក្នុងបរិយាកាសសេដ្ឋកិច្ចមួយដែលមានទំនាក់ទំនងល្អនៅក្នុងតំបន់។

តាមរយៈភាពជាដៃគូយុទ្ធសាស្ត្រនេះ ធនាគារ មេយប៊ែង និងសហគ្រិនខ្មែរ បានបញ្ជាក់ជាថ្មីនូវចក្ខុវិស័យរួមគ្នា ដើម្បីគាំទ្រដល់សហគ្រិន ពង្រឹងភាពធន់របស់សហគ្រាសធុនតូច និងមធ្យម និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន ដើម្បីរួមចំណែកដល់វឌ្ឍនភាពសេដ្ឋកិច្ចកម្ពុជារយៈពេលវែង ដើម្បីធានាឲ្យបានថាការគាំទ្រដល់អាជីវកម្មនៅតែមានភាពងាយស្រួល មានទំនួលខុសត្រូវខ្ពស់ និងមានការផ្តោតលើតម្រូវការជាក់ស្តែងរបស់សហគ្រាស និងសហគមន៍កម្ពុជា។